# វត្ថុសិល្បៈថ្មីៗ
# new artefacts

វត្ថុសិល្បៈថ្មីៗ
រៀបចំពិព័រណ៍ដោយ រ៉ជឺ នែលសិន

**new artefacts**

curated by Roger Nelson

អាល់ហ្វ្រេដូនិងអ៊ីសាបែល អាឃ្វីលីស្សាន
ALFREDO & ISABEL AQUILIZAN

ខ្វៃ សំណាង
KHVAY SAMNANG

ឃ្លែរ ម៉ាក់ក្រាក់ឃិន
CLARE McCRACKEN

ឌ្រូ ភិតទីហ្វឺរ
DREW PETTIFER

អេមីលីស៊ែនហ្វត
AMY LEE SANFORD

ស្វាយ គេន
SVAY KEN

ស្វាយ សារ៉េត
SVAY SARETH

គ្រីស្ទាន ថមសុន
CHRISTIAN THOMPSON

៩ សីហា ដល់ ២ កញ្ញា ២០១២

**9 August — 2 September 2012**

ស-សបាសាក់ SA SA BASSAC

# បុព្វកថា

ស.ស. បាសាក់ មានក្តីសោមនស្សនឹងធ្វើជាម្ចាស់ផ្ទះនៃពិព័រណ៍វត្ថុសិល្បៈថ្មី ដោយសហការណ៍ជាមួយអ្នករៀបចំពិព័រណ៍ឯករាជ្យ គឺលោក រ៉ជឺ នែលសិន និងគាំទ្រដោយស្ថានទូតអូស្ត្រាលី និងវិទ្យាស្ថាន បារាំង នៅកម្ពុជា។

ស.ស. បាសាក់ ជាវិចិត្រសាលនិងបណ្ណាល័យមួយដែលបង្កើតឡើងជាពិសេសសម្រាប់ពិព័រណ៍ និងការអប់រំសិល្បៈសហសម័យដែលរួមស្ថាបនាដោយក្រុមសិល្បករ ស្ទាវសិល្បៈ និង នាងខ្ញុំផ្ទាល់នៅដើមឆ្នាំ ២០១១។

ក្នុងការព្យាយាមកំណត់អត្តសញ្ញាណ និងឆ្លើយតបនឹងតម្រូវការក្នុងស្រុក ជុំដំបូងដែលមានរយៈពេល១៨ខែរបស់ ស.ស. បាសាក់ផ្តោតលើការកសាងគ្រឹះទ្រទ្រង់សម្រាប់សិល្បករនាំមុខក្នុងស្រុករបស់កម្ពុជាចំនួន១២នាក់ដោយរៀបចំពិព័រណ៍ទោលនូវស្នាដៃថ្មីៗ។ វិធីធ្វើនិងគំនិតស៊ីជម្រៅផ្សេងៗគ្នារបស់ពួកគេដោយអបជាមួយនឹងអត្ថបទបំផុសគំនិត និងកម្មវិធីមហាជនជាង ៣០លើក ផងបានទាក់ទាញទស្សនិកជន ក្នុងស្រុកបង្កើនចំណេះដឹងអំពីតួនាទីរបស់អ្នករៀបចំពិព័រណ៍ និងនាំសហគមន៍សិល្បៈ និងស្រាវជ្រាវ អន្តរជាតិឱ្យចូលរួមជាមួយខ្លឹមសារ និងបរិបទរបស់សិល្បករ។ សិល្បករម្នាក់ៗឥឡូវត្រូវបានទាក់ទងតាមរយៈការអញ្ជើញពីសំណាក់អ្នកនិពន្ធអ្នកស្រាវជ្រាវ ឬអ្នករៀបចំពិព័រណ៍ក្នុងស្រុកក្នុងតំបន់និងអន្តរជាតិ ឱ្យចូលរួមក្នុងគម្រោងជាច្រើន នាឆ្នាំក្រោយនេះ។

ខណៈដែល ស.ស. បាសាក់ នឹងបន្តជ្រៀតទៅមុខខាងពិព័រណ៍ទោលនៅទីតាំងរបស់យើងខ្ញុំ និងគាំទ្រសិល្បករក្នុងគម្រោងរបស់ពួកគេនៅក្រៅប្រទេសកម្ពុជា យើងខ្ញុំមានក្តីរំភើបនឹងការចូលដល់ជុំទី២នៃការរៀបកម្មវិធីរបស់យើងខ្ញុំដោយផ្តោតលើការដោះដូរគំនិតនៅកន្លែងយើងខ្ញុំ។ វត្ថុសិល្បៈថ្មីកំណត់នូវការចាប់ផ្តើមនៃការវិវត្តនេះ ហើយនិយាយយ៉ាងមុតមាំចំពោះគោលដៅរបស់ខ្លួនដោយផ្តល់នូវវេទិការៀបចំពិព័រណ៍ និងពិព័រណ៍ដល់អ្នកដទៃ។

អ្នករៀបចំពិព័រណ៍ រ៉ជឺ នែលសិន ជាអ្នកប្រចាំការឱ្យអាស៊ាលីងយ៍(Asialink) និងបេក្ខជនបណ្ឌិតអូស្ត្រាលី នៅសកលវិទ្យាល័យមែលប៊ន។ ការស្រាវជ្រាវរបស់គាត់ផ្តោតលើសិល្បៈសហសម័យពីប្រទេសកម្ពុជា។ វត្ថុសិល្បៈថ្មីប្រមូលផ្តុំសិល្បករខ្មែរក្នុងស្រុក និងខ្មែរក្រៅស្រុក ជាមួយសិល្បករអូស្ត្រាលីទាំងថ្មីថ្មោងនិងមានបទពិសោធន៍។ ពិព័រណ៍នេះបានគិតគូរក្នុងការសុំឱ្យមានការបកស្រាយថ្មីៗនៃដំណើរការរបស់សិល្បករ និងទុកឱកាសឱ្យពួកយើងបានដោះដូរគំនិត។

សូមអរគុណដល់ រ៉ជឺ អ្នកគាំទ្រពិព័រណ៍នេះ ទស្សនិកជន និងជាពិសេសសិល្បករដែលចូលរួម។

**អេរិន គ្លីសិន**

សហស្ថាបនិក និងប្រធានផ្នែកសិល្បៈ

ស.ស. បាសាក់

# Foreword

SA SA BASSAC is pleased to host the exhibition ***new artefacts*** in collaboration with independent curator Roger Nelson and supported by The Australian Embassy and Institute Francais, Cambodia.

SA SA BASSAC is a gallery and reading room exclusively dedicated to contemporary art exhibitions and education, co-founded by artist collective Stiev Selapak and myself in early 2011.

In seeking to identify and address local needs, SA SA BASSAC's first cycle of eighteen months focused on building a supportive foundation for twelve of Cambodia's leading local artists by curating solo exhibitions of new work. Their diverse practices and critical ideas — supported by thoughtful texts and over thirty public programs — drew local audiences, increased knowledge of the curatorial role, and engaged the international art and scholarly community with the artists' content and context. Each artist is now engaged by invitations from local, regional or international writers, scholars or curators in multiple projects over the next year.

While SA SA BASSAC will continue to thread in solo exhibitions in our space and support the artists in their projects outside Cambodia, we are excited to enter our second cycle of programming with a focus on exchange. As our artists exchange in new contexts, we invite others to exchange in ours. ***new artefacts*** marks the beginning of this evolution and speaks poignantly to its goals by extending the curatorial and exhibition platform to others.

Curator Roger Nelson is an Australian Asialink resident and PhD candidate at The University of Melbourne focusing his research on contemporary art from Cambodia. ***new artefacts*** brings together local and Cambodian diaspora artists with both emerging and established Australian artists. The exhibition considerately asks for new translations of artists' processes and offers us space for exchange of ideas.

Thank you to Roger, the supporters of this exhibition, our audiences, and especially to the participating artists.

**Erin Gleeson**
Co-Founder and Artistic Director
SA SA BASSAC

# សេចក្តីផ្តើម

វត្ថុសិល្បៈថ្មីរុករកដំណើរការតាមការពិសោធន៍ៈ នៅក្នុងវិធីធ្វើរបស់សិល្បករសហសម័យ និងជាបែបផែនចងក្រងឯកសារនិងពិព័រណ៍។ លើសពីនេះវត្ថុសិល្បៈថ្មីពិនិត្យនូវសក្តានុពលសម្រាប់ស្នាដៃសិល្បៈ និងវត្ថុដែលផ្សារភ្ជាប់សិល្បករ និងទស្សនិកជនដោយមានសុន្ទរកថានានាខាងស្រាវជ្រាវ និងប្លែកថ្មីដែលប្រសព្វគ្នាដែលកើតមានក្នុងតំបន់ និងលើឆាកអន្តរជាតិ។

ស្នាដៃ និងវត្ថុសិល្បៈនៅក្នុងវត្ថុសិល្បៈថ្មីត្រូវបាន«បន្សល់ទុក»ពីកន្លែងរបស់ខ្លួនផ្ទាល់ទៅតាមវិធីធ្វើឬដំណើរការការងាររបស់សិល្បករម្នាក់ៗ ហើយត្រូវបានរើចេញពីបរិបទដើមរបស់ខ្លួន។ វត្ថុដែលដាក់តាំងរួមមានសម្ភារៈធ្វើការកំណត់ត្រាឯកសារ និងរូបព្រាង។ ស្នាដៃសិល្បៈដែលដាក់តាំងរួមមានស្នាដៃដែលថ្មីបើហើយក្តីមិនសុីនឹងស៊េរីឬត្រូវបានកែចេញនៅពេលដំណើរការជ្រើសរើស ឬមិនត្រូវបានរាប់បញ្ចូលក្នុងពិព័រណ៍ណាមួយ។

ស្នាដៃ និងវត្ថុសិល្បៈដែលដាក់តាំងនីមួយៗត្រូវបានបម្រុងដើម្បីផ្តល់ចំណុចចេញដំណើរសម្រាប់កិច្ចសន្ទនា និងសំវាទអំពីព្រំដែនដែលត្រូវប្រកែកគ្នារវាងដំណើរការរបស់សិល្បករ និងផលិតផលសម្រេចរវាងគោលគំនិត និងសោភណភាព និង រវាងការចងក្រងឯកសារ និងស្នាដៃ«ពិត»។ ស្នាដៃ និងវត្ថុនីមួយៗប្រាប់យើងអំពីវិធីធ្វើរបស់សិល្បករនិងអំពីគំនិតដែលសិល្បកររូបនោះផ្សារភ្ជាប់ជាមួយ។

ការតាំងពិព័រណ៍នឹងប្រមូលផ្តុំទាំងសិល្បករថ្មីថ្មោង និងមានបទពិសោធន៍ហើយ មកពីប្រទេសអូស្ត្រាលីនិងកម្ពុជាដោយសម្របសម្រួលនូវលទ្ធភាពផ្លាស់ប្តូរឆ្លងវប្បធម៌រវាងប្រជាជាតិទាំងពីរ នៅសម័យក្រោយអាណានិគមខុសៗគ្នានិងមានប្រវត្តិសាស្ត្របន្ទាប់បន្សំផង។ សៀវភៅបញ្ជីវត្ថុសិល្បៈនិងសន្និសីទជំនាញក្នុងការពិភាក្សាជាសាធារណៈជាភាសាអង់គ្លេស និងខ្មែរនឹងបណ្តាលឱ្យមានកិច្ចសន្ទនាជាបន្តបន្ទាប់បន្ថែមទៀត។ សុន្ទរកថាខ្លះដែលវត្ថុសិល្បៈថ្មីផ្សារភ្ជាប់ជាមួយរួមមានៈភាពអត្តនោម័តនៅសម័យក្រោយអាណានិគមជាពិសេសវាទាក់ទងនឹងភាសា(គ្រីស្ទាន ថមសុន, ស្វាយ គេន)សហគមន៍ក្រៅស្រុក(អាល់ហ្វ្រេដូ និង អ៊ីសាបែល អាឃ្វីលីស្សាន, អេមី ស៊ែនហ្វត)ការចងចាំង និងរបួសអារម្មណ៍ក្រោយសង្គ្រាម(សេនហ្វដ, ស្វាយ គេន)ការសម្លឹងមើលរបស់អ្នកប្រតិព័ទ្ធភេទដូចគ្នានិងយន្តការនៃការថតចំណង់ផ្លូវភេទ(ឌ្រូ ភិតទីហ្វីរ)និងការចូលរួមរបស់សហគមន៍កន្លែងសាធារណៈនិងការតបត(ខ្វៃ សំណាង ឃ្លែរ ម៉ាក់ក្រាក់ឃិន)។

ពិព័រណ៍ប្រមូលផ្តុំទាំងសិល្បករថ្មីថ្មោង និងមានបទពិសោធន៍ហើយ មកពីប្រទេសអូស្ត្រាលី និងកម្ពុជាដោយសម្របសម្រួលនូវលទ្ធភាពការដោះដូរឆ្លងវប្បធម៌រវាងប្រជាជាតិទាំងពីរ នៅសម័យក្រោយអាណានិគមខុសៗគ្នានិងមានប្រវត្តិសាស្ត្របន្ទាប់បន្សំផង។ សេចក្តីស្នើដកពិសោធន៍របស់អ្នករៀបចំពិព័រណ៍ដែលទ្រទ្រង់ដល់វត្ថុសិល្បៈថ្មីត្រូវបានបម្រុងទុកដើម្បីធ្វើឱ្យមានន័យស្មើគ្នាសម្រាប់ទាំងសិល្បករចូលរួមជាតិអូស្ត្រាលី និងខ្មែរនិងសម្រាប់ទស្សនិកជនក្នុងស្រុក និងអន្តរជាតិ។

ក្នុងការណែនាំឱ្យវត្ថុសិល្បៈថ្មី ខ្ញុំបាទមានចំណាប់អារម្មណ៍លើសភាពរូប និងសោភណភាពនៃការរួមចំណែករបស់សិល្បករម្នាក់ៗ ដោយសារខ្ញុំបាទមានការផ្សារភ្ជាប់ខាងគោលគំនិតដែលសិល្បករកំពុងចង្អុលរក។ ពុំមានការផ្តល់អភ័យឯកសិទ្ធិដល់«វត្ថុសិល្បៈ» ឬ បរិបទរបស់វានោះទេ។ របស់ទាំងពីរត្រូវបានលើកសរសើរ ដោយសារបានផ្តល់ជាការសម្លឹងមើល និងគិតគូរជិតដល់ និងម៉ត់ចត់ជាវង្វាន់។

**រ៉ដើ នៃលសិន**

អ្នករៀបចំពិព័រណ៍

# Introduction

***new artefacts*** experimentally explores process: in the practice of contemporary artists, and also as a mode of documentation and exhibition. Furthermore, ***new artefacts*** examines the potential for artworks and objects to connect artists and audiences with various intersecting creative and scholarly discourses that occur regionally and internationally.

The artworks and objects in ***new artefacts*** have been "left over" from their proper place in each artist's practice or working process, and strategically removed from their original contexts. The exhibited objects include working materials, notes, documents and sketches; the exhibited artworks include pieces that, while finished, did not fit within a series, or were edited out in a selection process, or were not included in an exhibition.

Each of the exhibited objects and artworks are intended to provide departure points for conversations and dialogues about the contestable boundaries between the artist's process and finished product, between the concept and the aesthetic, and between the documentation and the "real" work. Each work and object tells us about the artist's practice, and about the ideas with which the artist engages. Some of the discourses with which ***new artefacts*** engages include: postcolonial subjectivity, especially as it relates to language (Christian Thompson, Svay Ken); diaspora communities (Alfredo & Isabel Aquilizan, Amy Lee Sanford); post-conflict memory and trauma (Sanford, Svay Sareth); the queer gaze and the mechanisms of recording desire (Drew Pettifer); and community participation, public space and resistance (Khvay Samnang, Clare McCracken).

The exhibition brings together both emerging and established artists from Australia and Cambodia, facilitating the possibility of cross-cultural exchange between these differently postcolonial and historically peripheral nations. The experimental curatorial propositions that underpin ***new artefacts*** are intended to be equally meaningful for both Australian and Cambodian participating artists, and for both local and international audiences.

In presenting ***new artefacts***, I am as interested in the physicality and aesthetic of each artist's contribution as I am in the conceptual connections to which the artists are pointing. Neither the 'artefact' nor its context is privileged; both are celebrated for rewarding close and careful looking and thinking.

**Roger Nelson**
Curator

# អាល់ហ្វ្រេដូ និងអ៊ីសាបែល អាឃ្វីលីស្សាន

ស្នាដៃរបស់ក្រុមគូស្វាមីភរិយាអាល់ហ្វ្រេដូ និង អ៊ីសាបែល អាឃ្វីលីស្សាន ត្រូវបានបង្កើតឡើងជាធម្មតា តាមរយៈដំណើរការប្រមូល និងសហការណ៍។ មានដើមកំណើតនៅហ្វីលីពីន ហើយឥឡូវរស់នៅនិងធ្វើការនៅប្រទេសអូស្ត្រាលី វិធីធ្វើរបស់គ្រួសារអាឃ្វីលីស្សាន គឺពិនិត្យមើលបទពិសោធន៍របស់បុគ្គល នៅក្នុងសហគមន៍ដែលមានការផ្លាស់លំនៅ និងផ្លាស់ប្តូរ និងអ្នកផ្លាស់ទីទៅក្រៅស្រុក។ ទាំងប្រទេសកំណើត និងប្រទេសស្នាក់នៅថ្មីរបស់គ្រួសារអាឃ្វីលីស្សានជាសង្គមក្រោយសម័យអាណានិគមដែលមានវប្បធម៌សំបូរបែប។ ហើយចំណុចនេះមានរំលេចក្នុងវិធីធ្វើបែបកំណាព្យតែពេញដោយន័យនយោបាយរបស់ពួកគាត់។

សម្រាប់ សម្រាប់ហោះហើរ (គម្រោងៈ ប្រទេសមួយទៀត) ក្នុងឆ្នាំ២០០៩ គ្រួសារអាឃ្វីលីស្សានបាននាំទស្សនិកជនឱ្យធ្វើ យន្តហោះលេងៗ ដោយប្រើសម្ភារៈតូចតាចដែលសិល្បករផ្តល់ឱ្យពួកគេ។ ធាតុលេងៗទាំងនេះ ជាច្រើនពាន់ត្រូវបានប្រមូល ក្នុងកន្លែងវិចិត្រសាលធំមួយ។ ដូចជាគម្រោងជាច្រើនរបស់សិល្បករគូនេះដែរ ស្នាដៃមានលក្ខណៈចម្លែកដោយភាពក្លាយផង គិតតាមភាពសំបូរបែបហួសប្រមាណនៃប្រភេទយន្តហោះ ដោយការលុបភាពខុសគ្នា គិតតាមមាត្រដ្ឋានគ្រង់ៗនៃការបង្កើនរបស់ពួកគេផង។ ក្តីបារម្ភចម្បងរបស់គ្រួសារអាឃ្វីលីស្សាន គឺមិនមែនជាមួយវត្ថុទាំងនោះផ្ទាល់ទេ តែគឺជាមួយដំណើរការនៃការបង្កើតវត្ថុនោះច្រើនជាង។

សម្រាប់ហោះហើរ ត្រូវបានតាំងពិព័រណ៍ដំបូង នៅកម្មវិធី៣ឆ្នាំម្តងប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកលើកទី៦ នៅវិចិត្រសាលសិល្បៈឃ្វីនស្លែនរបស់អូស្ត្រាលី។ សិល្បករទាំង២ក៏ត្រូវបានបញ្ចូលក្នុងកម្មវិធី ៣ឆ្នាំម្តងប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកលើកទី៣ ក្នុងឆ្នាំ១៩៩៩ ក្នុងកម្មវិធី៣ឆ្នាំម្តងនៃសិល្បៈអាស៊ីលើកទី១ នៅហ្វឹគឺអូកា ក្នុងឆ្នាំដដែល ហើយក្នុងកម្មវិធី២ឆ្នាំម្តងនៅវេនីស ឆ្នាំ២០០៣ ក្នុងចំណោមកម្មវិធីអន្តរជាតិឯទៀតជាច្រើន។ សម្រាប់វត្ថុសិល្បៈថ្មីការចងក្រងឯកសារមួយដែលរៀបចំជាពិសេសពី សម្រាប់ហោះហើរ បង្ហាញគំរូសក្តានុពលសម្រាប់អត្ថន័យថ្មី ដែលងើបឡើងតាមរយៈការបញ្ចូលរូបសណ្ឋានឡើងវិញដោយយកចិត្តទុកដាក់។

## Alfredo & Isabel Aquilizan

The work of husband and wife collaborative duo Alfredo & Isabel Aquilizan is typically made through processes of collecting and collaborating. Born in the Philippines and now living and working in Australia, the Aquilizans' practice examines the experiences of individuals within communities; of dislocation and change; and of migrant diasporas. Both the Aquilizans' country of birth and their new country of residence are culturally diverse postcolonial societies, and this is reflected in their poetic yet politically charged practice.

For 2009's *In-flight (Project: Another Country)*, the Aquilizans invited audiences to make toy airplanes, using humble materials provided to them by the artists. Many thousands of these playful relics were collected in a large gallery space. Like many of the artists' projects, the work was paradoxically both heterogeneous — in the staggering diversity of types of airplanes — and erasing of difference, in the sheer scale of their accumulation. The Aquilizans'primary concern is not with the objects themselves, but rather with the process of the objects being made.

*In-flight* was originally exhibited at the 6th Asia Pacific Triennial, at Australia's Queensland Art Gallery. The artists were also included in the 3rd Asia Pacific Triennial in 1999, in the 1st Asian Art Triennial in Fukuoka in the same year, and in the 2003 Venice Biennale, among many other international shows. For ***new artefacts***, a specially prepared documentation of *In-flight* demonstrates the potential for new meanings to arise through mindful reconfiguration.



អាល់ ហ្វ្រេដូ និង អ៊ីសាបែល អាឃ្វីលីស្សាន
សម្រាប់ហោះហើរៈ គម្រោង «ប្រទេសមួយទៀត» ឆ្នាំ២០០៩
កម្មវិធី៣ឆ្នាំម្តងប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកលើកទី៦
វិចិត្រសាលសិល្បៈឃ្វីនស្លែន/វិចិត្រសាលសិល្បៈទំនើប  ប្រ៊ីសបាន អូស្រ្តាលី
អនុញ្ញាតិឱ្យប្រើដោយសិល្បករ

Alfredo & Isabel Aquilizan
*In-Flight: Project Another Country*, 2009
Recycled materials, strings, sound files
6th Asia Pacific Triennale of Contemporary Art
Queensland Art Gallery/Gallery of Modern Art, Australia
Courtesy of the artists

# ខ្វៃ សំណាង

ក្នុងវិធីធ្វើដែលផ្អែកលើស៊េរីរបស់គាត់ ខ្វៃ សំណាងប្រើភាពកំប្លែងស្ងួត និងភាពប៉ិនប្រសប់ ដែលចាំបាច់តាមយុទ្ធសាស្រ្ត ដើម្បីពិនិត្យមើលទិដ្ឋភាពនានានៃវប្បធម៌ខ្មែរបច្ចុប្បន្ន។ គាត់ច្រើនតែផ្តោតលើការផ្លាស់ប្តូរ និងការបន្ត ដូចក្នុងស៊េរីគ្មានចំណងជើង ឆ្នាំ២០១១របស់គាត់ ដែលថតនៅទីតាំងផ្ទាល់ នៅបឹងបីបួនកន្លែង ក្នុងនិងជុំវិញភ្នំពេញ។ ស៊េរីនេះចងក្រងឯកសារអំពីបឹង ទាំងនេះ ពេលដែលវាកំពុងបាត់បង់ៈ បឹងត្រូវបានលុបដោយខ្សាច់ដើម្បីបើកផ្លូវឱ្យការអភិវឌ្ឍន៍ ឯកជន។ នៅបឹងកក់ ដែលជាបឹងធំជាងគេ ឃើញមានមនុស្សជាង៤០០០គ្រួសារត្រូវបណ្តេញចេញទាំងបង្ខំ ដោយសាររឿងចម្រូងចម្រាសមួយដែលនៅតែទាក់ទាញចំណាប់អារម្មណ៍ ក្នុងស្រុកនិងអន្តរជាតិ។

សម្រាប់វត្ថុសិល្បៈថ្មី សំណាងនឹងតាំងជាលើកដំបូងនូវវីដេអូ៦ ដែលចងក្រងជាឯកសារនូវការផលិតស្នាដៃ គ្មានចំណងជើង ដែលតឹងតែងខ្លាំង ហើយច្រើនតែប្រកបដោយគ្រោះថ្នាក់។ ការចងក្រងឯកសារមានឈុតឆាក តែធ្វើទៅដោយឯកឯង បញ្ច្រាសនឹងឈុតដកចេញ និងកំណែដែលមានការជុះខាត់ដែលសំណាងរាប់ថា «សម្រេច» សម្រាប់ពិព័រណ៍ទោលឆ្នាំ២០១១របស់គាត់។

ខ្វៃ សំណាង បញ្ចប់បរិញ្ញាប័ត្រមកពីសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ គាត់រស់នៅ និងធ្វើការនៅភ្នំពេញ។ សំណាងជាសមាជិកសកម្មរបស់ក្រុមសិល្បករ ស្ទាវសិល្បៈ និងជាសហស្ថាបនិករបស់គម្រោងសិល្បៈ ស.ស.ដែលជាកន្លែងដែលគ្រប់គ្រងដោយសិល្បករមានតែមួយនៅកម្ពុជា។ ចាប់តាំងពីបានទទួលធ្វើនិវេសនដ្ឋានប្រកបដោយកិត្យានុភាពនៅទីតាំងអច្ឆរិយៈ តូក្យូ ក្នុងឆ្នាំ២០១០ និង២០១១រួចមក ស្នាដៃសំណាងបានផ្តោតលើការថតរូបវីដេអូ និងការសម្តែង។ គាត់ជាបុគ្គលសំខាន់ក្នុងការចែករំលែកគោលគំនិត និងជំនាញដែលទាក់ទងនឹង ទម្រង់វិធីធ្វើដែលនៅមានតិចនៅឡើយនេះ ក្នុងចំណោមសិល្បករដូចគ្នា។

# Khvay Samnang

In his series-based practice, Khvay Samnang uses humour and strategically necessary subtlety to examine various aspects of contemporary Cambodian culture. He often focuses on change and continuity, as in his 2011*Untitled* series, which was shot on location in several lakes in and around Phnom Penh. This series documents these lakes as they disappear: they are being filled with sand in order to make way for private developments. The largest, Boeung Kak Lake, has seen over 4000 families forcibly evicted in a controversy that continues to draw local and international attention.

For ***new artefacts***, Khvay exhibits for the first time six videos that document the arduous, often dangerous making of *Untitled*. This staged yet spontaneous documentation contrasts with the polished edits that Khvay presented as 'finished' for his 2011 solo exhibition.

Holding a Bachelors degree from the Royal University of Fine Arts, Khvay Samnang lives and works in Phnom Penh. An active member of artists' collective Stiev Selapak ('Art Rebels'), Khvay is a co-founder of Sa Sa Art Projects, Cambodia's only artist-run space. Since undertaking a prestigious residency at the Tokyo Wonder Site in 2010 and 2011, Khvay's work has centred on photography, video and performance. He has been instrumental in sharing concepts and skills related to these still marginal forms of practice among his peers.



ខ្វៃ សំណាង
គ្មានចំណងជើង (បឹងជើងឯក) ២០១១
រូបថតប្រភេទ C
ថតដោយ វណ្ឌី រតនា
អនុញ្ញាតិឱ្យប្រើដោយសិល្បករ និងស.ស. បាសាក់

Khvay Samnang
*Untitled (Boeung Cheung Ek),* 2011
C-type photograph
Photography by Vandy Rattana
Courtesy of the artist and SA SA BASSAC

# ឃ្លែរ ម៉ាក់ក្រាក់ឃិន

ឃ្លែរ ម៉ាក់ក្រាក់ឃិន ជាសិល្បករមហាជនដែលមានបទពិសោធន៍ ដោយមានការដំឡើងទាំង បណ្តោះអាសន្ន ទាំងអចិន្ត្រៃយ៍ពាសពេញទីសាធារណៈនៅមែនប៊ិន អូស្ត្រាលី។ គាត់ក៏ជាសិល្បករវិចិត្រសាលថ្មីថ្មោងដែរៈ ពិព័រណ៍ទោលដំបូងរបស់គាត់ត្រូវបានរៀបចំ នៅឆ្នាំ២០១១។ ទាំងក្នុងការដំឡើងជាសាធារណៈ និងវិធីធ្វើដែលផ្អែកលើស្ទូឌីយោរបស់គាត់ ស្នាដៃរបស់ ម៉ាក់ក្រាក់ឃិនមានការផ្តោតអារម្មណ៍លើការកំប្លែងស្ងួត អន្តរភាពចម្លែកៗ និងអានុភាពនៃការលេងដោយមានការចូលរួម។

ថ្ពាល់ល្បឿន ជាការដំឡើងអចិន្ត្រៃយ៍មួយនៅ ណូបលផាក ដែលជាតំបន់ជាយក្រុងពហុវប្បធម៌បំផុតរបស់មែលប៊ិន (ដោយមានប្រជាជន៥០%កើតនៅបរទេស) ហើយជាចៃដន្យ ជាកន្លែងប្រមូលផ្តុំសហគមន៍អ្នកផ្លាស់ទីកម្ពុជាដ៏ធំ និងរស់រវើក។ ស្នាដៃនេះត្រូវបានឧបត្ថម្ភឱ្យធ្វើដោយ ក្រុមប្រឹក្សាក្នុងស្រុក ដើម្បីដំណើរការដីឧទ្យានសាធារណៈមួយដែលត្រូវបានរងការប៉ះពាល់យ៉ាងខ្លាំងដោយការអភិវឌ្ឍន៍ផ្លូវបង់ប្រាក់ខ្នាតធំ ឆ្លងកាត់តំបន់ជាយក្រុងនោះ។ ថ្ពាល់ល្បឿន បង្ហាញពីល្បឿនអ្នកថ្មើរជើងពេលពួកគេដើរ រត់ ឬជិះកង់កាត់ ដោយយោងជារបៀបលេងសើចដល់ឧបករណ៍ស្រដៀងគ្នាដែលដំឡើងដោយអជ្ញាធរ នៅតាមផ្លូវនៅក្បែរ។

សម្រាប់វត្ថុសិល្បៈថ្មី ម៉ាក់ក្រាក់ឃិនតាំងបង្ហាញការចងក្រងឯកសារនូវរាល់ដំណាក់កាលនៃគម្រោង ថ្ពាល់ល្បឿន តាំងពីការបង្កើតគោលគំនិតរបស់គាត់ ឆ្លងតាមការដាក់ពាក្យសុំមូលនិធិបែបការិយាល័យធិបតេយ្យ និងដំណើរការដ៏ស្វិតស្វាញដល់ការសម្រេចចុងក្រោយដែលផ្អែកខ្លាំងលើការងារម៉ៅការបន្ត។ ក្នុងបទបង្ហាញមួយ នៅគម្រោងសិល្បៈ ស.ស. ក្នុងខែមិថុនា២០១២ សិល្បកររូបនេះបាននិយាយពីការយល់ឃើញ និងការប្រើប្រាស់ផ្សេងគ្នានូវកន្លែង សាធារណៈ និងលទ្ធភាពសម្រាប់សិល្បៈមហាជន ក្នុងបរិយាកាសរស់រវើក និងប្រែប្រួលយ៉ាងលឿន ដូចភ្នំពេញ។

# Clare McCracken

An established public artist with dozens of both temporary and permanent installations throughout public sites in Melbourne, Australia, Clare McCracken is also an emerging gallery artist: her first solo show was held in in 2011. In both her public installations and her studio-based practice, McCracken's work has an emphasis on quirky humour, interactivity, and the enlisting power of play.

*Speed Cheek* is a permanent installation in Noble Park, Melbourne's most multicultural suburb (with over 50% of its population born overseas) and, incidentally, home to a large and vibrant Cambodian migrant community. The work was commissioned by the local Council to activate a public parkland that had been drastically affected by the development of a large-scale toll road through the suburb. *Speed Cheek* displays the speed of pedestrians as they walk, run or cycle past, playfully referencing similar devices installed by authorities along nearby roads.

For ***new artefacts***, McCracken exhibits documentation of all stages of the *Speed Cheek* project, from the development of her concept, through the bureaucratic funding application and tender process, to the final realisation which relied heavily on subcontracted labour. In a presentation at Sa Sa Art Projects in June 2012, the artist spoke of differing understandings and uses of public space, and of the possibilities for public art in a dynamic and rapidly transforming environment like Phnom Penh.



ឃ្លែរ ម៉ាក់ក្រាក់ឃិន
ថ្គាល់ល្បឿន ២០០៨
ការដំឡើងអចិន្ត្រៃយ៍ ជាមួយដែកថែប និងបង្ហាញដោយប្រើLED។ ណូបល ផាក មែលប៊ន អូស្ត្រាលី
អនុញ្ញាតិឱ្យប្រើដោយសិល្បករ

Clare McCracken
*Speed Cheek*, 2008
Permanent installation with steel and LED display. Noble Park, Melbourne, Australia
Courtesy of the artist

# ឌ្រូ ភិតទីហ្វឺរ

ដោយធ្វើការភាគច្រើនជាមួយហ្វីល៣៥ ម.ម. ក្នុងពន្លឺចៃដន្យ កិត្តិស័ព្ទរបស់ ឌ្រូ ភិតទីហ្វឺរនៅ អូស្ត្រាលី គឺសាងលើស្ទីលមិនផ្លូវការ និងបែបទិន្នានុលេខ។ ស្នាដៃរបស់គាត់សឹងតែទាំងអស់សុទ្ធតែជារូបមនុស្ស ភាគច្រើនរូបអាក្រាត ឬមិនដូច្នោះទេគឺរូបទាក់ទងច្រើននឹងផ្លូវភេទរបស់បុរសវ័យក្មេង។ មនុស្សសម្រាប់គូរភាគច្រើន គឺជាមិត្តភក្តិ គូស្នេហ៍ និងសហការីរបស់សិល្បករ។ ស្ទីលសារភាពរបស់ភិតទីហ្វឺរ និងភាពលាំៗកក់ក្តៅដ៏សំបូរបែបបានទទួលការប្រៀបធៀបទៅនឹង ណាន ហ្គូលឌីន និងរ៉ៃអាន ម៉ាកហ្គិនលី។ ភិតទីហ្វឺរ តាំងពិព័រណ៍តាំងពីឆ្នាំ២០០៧ គាត់បានបោះពុម្ពឯកលេខនាមួយនៃការងាររបស់គាត់ ក្នុងឆ្នាំ២០១២។ គាត់បញ្ចប់បរិញ្ញាប័ត្រខាង គ្រប់គ្រងសិល្បៈ សិក្សាវប្បធម៌ និងច្បាប់ ហើយសព្វថ្ងៃកំពុងបន្តរៀនយកអនុបណ្ឌិតផ្នែក វិចិត្រសិល្បៈ នៅសកលវិទ្យាល័យម៉ូណាស។

ទោះបីភិតទីហ្វឺរត្រូវបានស្គាល់ភាគច្រើនជាអ្នកថតរូបគាត់ក៏បានធ្វើការផ្នែកវីដេអូ សម្តែង និង ប្រព័ន្ធផ្សព្វផ្សាយថ្មីដែរ។ ពិព័រណ៍ទោលឆ្នាំ២០១២ឈ្មោះថា ការផ្ទេរ រួមមានចង្កៀងដែលភ្លឺព្រឹមៗ និងភ្លឺជាជុំបន្តបន្ទាប់។ សេកង់នេះហាក់មើលទៅនៅព្រាវ តែតាមពិតទៅត្រូវបានសរសេរតាមរលកសំលេងដែលបង្កើតដោយការថតសំលេងបុរសវ័យក្មេង ដែលប្រព្រឹត្តផ្លូវភេទដោយខ្លួនឯង។ ស្នាដៃនេះ ដែលជាស្នាដៃដំបូងរបស់សិល្បករ ដោយពុំមានធាតុរូបថត បន្តការរុករករបស់ភិតទីហ្វឺរ នូវចំណង់ផ្លូវភេទរបស់អ្នកប្រតិព័ទ្ធភេទដូចគ្នា ភាពជាប្រុស និងតួនាទីសន្ទាការីរបស់ឧបករណ៍ថត ក្នុងការតំណាងឱ្យការសម្លឹងមើលបែបរោគស្នេហា។

វត្ថុតាំងបង្ហាញក្នុងវត្ថុសិល្បៈថ្មី គឺជារូបថតដែលចងក្រងឯកសារនូវដំណើរការថត ការផ្ទេរ ក៏ដូចជាការដំឡើង។ រូបទាំងនេះត្រូវបានត្រៀមសម្រាប់សៀវភៅបញ្ជីវត្ថុសិល្បៈ តែមិនត្រូវបានបញ្ចូលក្នុងពិព័រណ៍ ការផ្ទេរ ទេ។

# Drew Pettifer

Working primarily with 35mm film in incidental light, Drew Pettifer's reputation in Australia is built on an informal, diary-like style. His works are almost exclusively portraits, often nudes or otherwise sexualised images, largely of young men. Many of the subjects are the artist's friends, lovers and colleagues; Pettifer's confessional style and richly warm hues have earned comparisons to Nan Goldin and Ryan McGinley. Exhibiting since 2007, Pettifer published a monograph of his work in 2012. He holds degrees in arts management, cultural studies and law, and is currently pursuing a Master of Fine Art at Monash University.

Although Pettifer is primarily known as a photographer, he has also worked in video, performance, and new media. The 2012 solo exhibition *Transmission* consisted of lamps that dimmed and brightened in a continuous cycle. The sequence appeared random, but was in fact dictated by soundwaves generated by an audio recording of young men masturbating. This work, the artist's first without any photographic element, continues Pettifer's explorations of queer desire, masculinity, and the mediatory role of the recording device in representing the erotic gaze.

The objects exhibited in ***new artefacts*** are photographs documenting the process of recording *Transmission*, as well as its installation. These images were prepared for the catalogue but were not included in the exhibition of *Transmission*.



ឌ្រូ ភិតទីហ្វឺរ
រូបថតដែលចងក្រងឯកសារស្ទូឌីយោថតសំលេងសម្រាប់ ការផ្ទេរ ២០១២
ពិព័រណ៍ទោល នៅ ក្រាហ្វ វិកថូរា មែលប៊ិន អូស្រាលី
រូបថតប្រភេទ C
អនុញ្ញាតិឱ្យប្រើដោយសិល្បករ

Drew Pettifer
Recording studio for *Transmission*, 2012
Solo exhibition, Craft Victoria, Australia
C-type photograph
Courtesy of the artist

# អេមី លី ស៊ែនហ្វត

នៅក្នុងការសម្តែងរយៈពេលមួយសប្តាហ៍នៅក្នុងខែមីនា ឆ្នាំ២០១២ អេមីលីស៊ែនតបានបំបែក ហើយបន្ទាប់មកបានបិទការឡើងវិញ នូវភាជន៍ចំនួន២០ដែលធ្វើពីដីឥដ្ឋ ដែលបានមកពីខេត្តកំពង់ឆ្នាំងដែលជាខេត្តកំណើតរបស់ឪពុកគាត់។ ស្នាដៃនេះដែលមានចំណងជើងថាវង្វង់ពេញ បានបរិយាយពីការរុករកជាបន្តបន្ទាប់របស់សិល្បករូបនេះនូវឥទ្ធិពលយូរអង្វែងនៃសង្គ្រាមនិងការរងទុក្ខ ដែលរួមមាន ពិរុទ្ធភាព ការនិរាសខ្ចាត់ខ្ចាយ និង ការបាត់បង់។ ស៊ែនហ្វត បានកើតនៅប្រទេសកម្ពុជា ប៉ុន្តែត្រូវបានចិញ្ចឹមនិងទទួលការអប់រំនៅសហរដ្ឋអាមេរិកដោយ ម្តាយចិញ្ចឹមរបស់គាត់ដែលមានសញ្ជាតិស៊ុយអែត-អាមេរិកាំង។ ឪពុកនិងសាច់ញាតិផ្សេងៗទៀតរបស់គាត់ ត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហមក្នុងចន្លោះឆ្នាំ១៩៧៥—៧៩។ វិធីធ្វើរបស់ សិល្បកររូបនេះតាមរយៈសម្ភារៈសាមញ្ញនិងក្នុងស្រុក និងកាយវិការបែបកំណាព្យនិយាយពីការបាត់បង់របស់គាត់ និងមានអត្ថិភាពជា«ជំនូន»ដល់មនុស្សនិងសហគមន៍ផ្សេងៗទៀតនៅទូទាំងប្រទេសកម្ពុជា និងលើឆាកអន្តរជាតិ ដែលជីវិតរបស់ពួកគេត្រូវបានប្រែប្រួលដោយសារជម្លោះហិង្សា។

ស៊ែនហ្វតមានសញ្ញាប័ត្រផ្នែកសិល្បៈ វិទ្យាសាស្ត្រ និងវិស្វកម្ម ពីសាកលវិទ្យាល័យប្រោន និង ហាវ៉ាដ សាលារចនារ៉ូដអាយលែន និង សាកលវិទ្យាល័យម៉ាសាឈូសេត/ដាតម៉ៅស៍។ គាត់បានមករស់នៅ និងធ្វើការនៅទីក្រុងភ្នំពេញចាប់តាំងពីឆ្នាំ២០០៦ដែលដំណាលពីបទពិសោធន៍នៃការវិលត្រឡប់មកកាន់ប្រទេសកំណើតរបស់ខ្លួន។

វង្វង់ពេញ ត្រូវបានចងក្រងជាជាឯកសារយ៉ាងទូលំទូលាយ រូបថតជាង៤០០០០សន្លឹកត្រូវបានថតដោយកាម៉េរ៉ាមួយដោយមានឧបករណ៍មុខងារពេលវេលាស្វ័យប្រវត្តិ ហើយភាជន៍ធ្វើពីដីឥដ្ឋដែលត្រូវបានផ្គុំឡើងវិញត្រូវបានផ្តល់ជាស្នាដៃសិល្បៈសម្រេច។ សម្រាប់វត្ថុសិល្បៈថ្មីៗ ស៊ែនហ្វតបង្ហាញស្នាដៃដែលកំពុងធ្វើ ដែលទាញចេញមកពីដំណើរការច្នៃនិងបញ្ចូលរូបសណ្ឋានឡើងវិញដែលកំពុងមាន នូវការចងក្រងឯកសាររូបថតនេះ។ សិល្បកររូបនេះកំពុងរៀបចំខ្សែវីដេអូ និង/ឬការដំឡើងមួយសម្រាប់ការតាំងពិព័រណ៍នាពេលអនាគត។

# Amy Lee Sanford

In a week-long performance in March 2012, Amy Lee Sanford smashed and then meticulously glued back together forty clay pots from Kompong Chhnang, the province where her father was born. This performance, *Full Circle*, elaborated the artist's continuing exploration of the lasting effects of war and trauma, including guilt, displacement and loss. Sanford was born in Cambodia, but raised and educated in the United States of America by her Swedish-American adoptive mother. Her father and many other relatives were killed during the Khmer Rouge regime of 1975—79. The artist's practice, through simple, vernacular materials and poetic gestures, speaks of her loss and exists as a kind of 'offering' to other individuals and communities around Cambodia and internationally whose lives have been transformed by violent conflict.

Sanford holds degrees in art, science and engineering from Brown and Harvard Universities, The Rhode Island School of Design and the University of Massachusetts/Dartmouth. She has lived and worked in Phnom Penh since 2006, lyrically narrating the experiences of the returning diaspora.

*Full Circle* was extensively documented — over 40,000 photographs were taken by a camera on automatic timer — and the reassembled clay pots were offered as finished artworks. For ***new artefacts***, Sanford presents a work in progress, drawn from her ongoing processing and reconfiguring of this photographic documentation. The artist is preparing a video and/or installation for future exhibition.



អេមី លី ស៊ែនហ្វត
រង្វង់ពេញ ២០១២
ការសម្តែងនៃរយៈពេល ជាមួយភាជន៍ធ្វើពីដីឥដ្ឋចំនួន៤០ ខែមីនា ២០១២
រូបថតដោយ ជាន ឡុង
អនុញ្ញាតិឱ្យប្រើដោយសិល្បករ និងចាវ៉ាអាត

Amy Lee Sanford
*Full Circle*, 2012
Durational performance, with 40 clay pots, March 2012
Photograph by Chean Long
Courtesy of the artist and JavaArts

# ស្វាយគេន

ស្វាយ គេន(១៩៣៣—២០០៨)ត្រូវបានចាត់ទុកជាតួអង្គស្ថាបនិកមួយរូបនៃសិល្បៈសហសម័យនៅក្នុងប្រទេសកម្ពុជា។ រូបគំនូរលើផ្ទាំងក្រណាត់នានារបស់គាត់ បង្ហាញជាទូទៅនូវរូបភាពប្រចាំថ្ងៃនៅក្នុងជីវិតរស់នៅរបស់ប្រជាជនសាមញ្ញកម្ពុជា។ សិល្បករដែលមិនធ្លាប់បានទទួលការអប់រំជាផ្លូវការក្នុងផ្នែកសិល្បៈរូបនេះ បានរក្សាការផ្ដោតពិសេសមួយទៅលើរូបមនុស្សនិងរូបភាពផ្អែកលើការនិទាន។ ស្នាដៃគំនូររបស់គាត់ ផ្ដល់នូវប្រវត្តិសាស្ត្ររស់រវើកអំពីភាពវឹកវរអស់ពាក់កណ្ដាលសតវត្ស ដែលពណ៌នាទស្សនីយភាពនៃសម័យអាណាព្យាបាលបារាំង ដែលបន្ដពីនោះគឺសម័យឯករាជ្យ សម័យកាន់កាប់ដោយកងទ័ពជប៉ុន សម័យលន់ណុលនៅដើមទសវត្ស១៩៧០ របបខ្មែរក្រហមនៅចន្លោះឆ្នាំ ១៩៧៥—១៩៧៩ ការកាន់កាប់ដោយកងទ័ពវៀតណាមក្នុងពេញទសវត្សទី១៩៨០ និងជាចុងក្រោយពីការមកដល់នៃអង្គការសហប្រជាជាតិនៅដើមទសវត្សទី១៩៩០។

ស្វាយ គេនគឺជាជនជាតិខ្មែរទីមួយដែលធ្វើការពិព័រណ៍នៅក្នុងឆាកអន្ដរជាតិ នៅកម្មវិធីពាឆ្នាំម្ដងពីសិល្បៈអាស៊ីលើកទីមួយនៅក្នុងទីក្រុងហ្វីគឺអូកា នៅក្នុងឆ្នាំ១៩៩៩ ហើយគឺម្នាក់ក្នុងចំណោមសិល្បករកម្ពុជាបួនរូបដែលត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីពាឆ្នាំម្ដងបស់ អាស៊ីប៉ាស៊ីហ្វិក ដែលមាននៅក្នុងឆ្នាំ២០០៩។ស្នាដៃរបស់គាត់ត្រូវបានប្រមូលដោយសារមន្ទីរនិងស្ថាប័នផ្សេងៗទៀតនៅពេញទូទាំងតំបន់ និងលើឆាកអន្ដរជាតិ។

វត្ថុសិល្បៈថ្មីៗរួមបញ្ចូលនូវផ្ទាំងក្រណាត់មួយដែលសិល្បកររូបនេះបានប្រើជាបន្ទះសម្រាប់លាយពណ៌និងសំអាតជក់មួយបែប។ ផ្ទាំងគំនូរនេះ គឺមានលក្ខណៈមិនតំណាង ដូចផ្ទាំងគំនូរ «សម្រេច»របស់គាត់ឡើយ។ គាត់បានព្យួរផ្ទាំងក្រណាត់នេះនៅជណ្ដើរដែលសំដៅទៅដល់ផ្ទះ/ស្ទូឌីយ៉ូរបស់គាត់។ យើងប្រហែលជាស្រមៃគិតថា គាត់បានប្រើប្រាស់វាជាសញ្ញានាំផ្លូវមួយប្រភេទសម្រាប់អ្នកទស្សនាដែលមកជួបគាត់ ហើយគិតថាវាប្រើជាឯកសារមួយនៃដំណើរការច្នៃប្រឌិតរបស់គាត់។

# Svay Ken

The late Svay Ken (1933—2008) is regarded as a founding figure of contemporary art in Cambodia. His paintings on canvas typically depict everyday scenes in the lives of ordinary Cambodians. The artist, who had no formal art education, maintained a particular focus on portraiture and narrative-based images. His paintings offer a vivid history of half a century of tumult, depicting scenes from the French Protectorate period, followed by independence, occupation by Japanese forces, Lon Nol's reign in the early 1970s, the Khmer Rouge regime of 1975—1979, occupation by Vietnamese forces throughout the 1980s, and finally the arrival of the United Nations in the 1990s.

Svay was the first Cambodian to exhibit in the international arena, at the 1st Asian Art Triennial in Fukuoka in 1999, and was one of four Cambodian artists to be included in the Asia Pacific Triennial in 2009. His works are collected by museums and other institutions throughout the region and internationally.

***new artefacts*** includes a canvas that the artist used as a kind of palette for mixing paint and cleaning brushes. Unlike his "finished" paintings, this piece is non-representational.The artist hung this canvas in the stairwell leading to his home/studio. We might imagine that he used it as a kind of direction sign for visitors coming to meet him, and it serves as a document of his creative process.



ស្វាយ គេន
២០០៦
ប្រេងលើផ្ទាំងក្រណាត់
អនុញ្ញាតិឱ្យប្រើដោយលោក ឈឹម សុធី ដោយអរគុណចំពោះលោក ស្វាយ ពិសិទ្ធ និងក្រុមគ្រួសាររបស់លោក ស្វាយ  គេន

Svay Ken
2006
Oil on canvas
Courtesy of Mr Chhim Sothy
With thanks to Mr Svay Pisith and the Svay Ken family

# ស្វាយ សារ៉េត

វិធីធ្វើរបស់ស្វាយ សារ៉េតដែលផ្អែកលើការសម្តែង និងដំឡើងភាគច្រើន បានរួមបញ្ចូលនូវការចែករំលែករឿងរ៉ាវរបស់គាត់ទន្ទឹមនឹងការកែឆ្នៃលទ្ធផលរបស់រឿងនោះ។ ដោយត្រូវបានចិញ្ចឹមនៅក្នុងជំរុំជនភៀសខ្លួននៅក្នុង និងជាប់ព្រំដែនប្រទេសកម្ពុជាដែលខ្ទេចខ្ទាំដោយសារសង្គ្រាមរហូតដល់អាយុ១៩ឆ្នាំ សារ៉េតថ្មីៗនេះបានប្រកាសខ្លួនឯងថាបាន «ទទួលរងជំងឺម្យ៉ាងដែលមានឈ្មោះថា 'អតីតកាល'»។ សិល្បកររូបនេះត្រូវបានស្គាល់ដោយសារការសម្តែងរយៈវែងពិបាកជាមួយនឹងវត្ថុទំហំធំ។ សម្រាប់សារ៉េត ការពិព័រណ៍ស្នាដៃនេះ ជាទូទៅមានលក្ខណៈបន្ទាប់បន្សំចំពោះដំណើរការឆ្នៃប្រឌិតរបស់គាត់។ នៅក្នុងការពិព័រណ៍នានា ភាគច្រើនតែងតែមានវត្ថុនិងឯកសារវីដេអូមួយស្តីពីការធ្វើដំណើររបស់សិល្បកររូបនេះ។

សារ៉េត ធ្លាប់ជាកុមារម្នាក់ក្នុងចំណោមកុមារមួយក្រុមតូចមួយដែលបានសិក្សាសិល្បៈនៅក្នុងជំរំជនភៀសខ្លួនសាយធូ ( Site II )។ បន្ទាប់មក ពួកគេបានបន្តការសិក្សាជាមួយគ្នានៅសាលាពន្លឺហ្វារសិល្បៈ ក្នុងខេត្តបាត់ដំបង ដែលជាអង្គការក្រៅរដ្ឋាភិបាលនិងសាលាសិល្បៈឯកជនមួយ ដែលសព្វថ្ងៃនេះកំពុងបន្តរីកចម្រើន។ សារ៉េតបានបន្តការសិក្សានៅប្រទេសបារាំង និងទទួលបានអនុបណ្ឌិតរបស់ខ្លួន ក្នុងឆ្នាំ២០០៩។

សម្រាប់ស្នាដៃឆ្នាំ២០១១ដែលមានចំណងជើងថាប៊ូលរបស់ខ្ញុំ សារ៉េតបានអូសប៊ូលប្រាក់ធំមួយ( ដែលមានអង្កត់ផ្ចិត២ម៉ែត្រនិងទម្ងន់៨០គ.ក្រ )ពីផ្ទះនៅខេត្តសៀមរាបរបស់គាត់ទៅទីក្រុង ភ្នំពេញ។ក្នុងរយៈ៦ថ្ងៃនៃការធ្វើដំណើរ សារ៉េតបានបរិភោគតែអាហារដែលផ្តល់ឱ្យគាត់ដោយមនុស្សដែលមិនដែលស្គាល់គ្នាតែប៉ុណ្ណោះ។ គាត់បានគេងនៅលើក្រណាត់តង់ពណ៌ខៀវ ដែលជាក្រណាត់ដែលប្រើប្រាស់ជាទូទៅដោយជនភៀសខ្លួនទូទាំងពិភពលោក។ ការពិព័រណ៍ដែលលេចចេញមក បង្ហាញនៅវិទ្យាស្ថានបារាំងនៅភ្នំពេញក្នុងឆ្នាំ២០១២ បានបញ្ចូលប៊ូលប្រាក់និងឯកសារវីដេអូមួយដែលមានរយៈពេល២០នាទីដែលផ្តោតទៅលើសិល្បកររូបនេះ។ នៅក្នុងវត្ថុសិល្បៈថ្មីៗ សារ៉េតធ្វើការបង្ហាញការជ្រើសរើសឈុតវីដេអូវែងជាងមុនមួយ ដែលរួមមានផងដែរនូវអន្តរកម្មជាមួយសមិទ្ធិករភាពយន្តនិងអ្នកដើរកាត់ ក៏ដូចជាក្រណាត់តង់ផងដែរ។

# Svay Sareth

Much of Svay Sareth's performance and installation-based practice has involved sharing his story while processing its effects. Raised in refugee camps in and bordering war-ravaged Cambodia until the age of 19, Svay recently declared himself to be "suffering from a sickness called 'the past.'" The artist is known for rigorous durational performances with large-scale objects. For Svay, exhibiting such work has typically been secondary to his creation process. Exhibitions most often comprise the object and a video document of the artist's journey.

Svay was one of a small group of children who studied art in the Site II refugee camps. Together they went on to co-found Battambang's Phare Ponleu Selpak, a private non-governmental organization and art school that continues to thrive today. Svay continued graduate studies in France and earned his Masters in 2009.

For 2011 performance *Mon Boulet*, Svay pulled a silver sphere — two meters in diameter and weighing 80 kilograms — from his Siem Reap home to Phnom Penh. Along the six day journey, Svay ate only food offered to him by strangers. He slept on a blue tarpaulin, the kind familiar to refugees worldwide. The resulting exhibition, presented at Phnom Penh's Institut Français in 2012, included the silver sphere and a 20-minute video documentcentred on the artist. In ***new artefacts***, Svay presents a longer selection of video footage, which also includes interactions with the filmmaker and passersby, as well as the tarpaulin itself.



ស្វាយ សារ៉េត
ប៉ូលរបស់ខ្ញុំ ២០១១
ការសម្តែង កម្ពុជា
រូបថតដោយ ខ្វៃ សំណាង
អនុញ្ញាតិឱ្យប្រើដោយសិល្បករ និងស.ស. បាសាក់

Svay Sareth
*Mon Boulet*, 2011
Performance, Cambodia
Photograph by Khvay Samnang
Courtesy the artist and SA SA BASSAC

# គ្រីស្ទាន ថមសុន

ទោះបីជាច្រើនត្រូវបានស្គាល់ថាជាជាងថតរូបមួយរូបក្តី គ្រីស្ទាន ថមសុនក៏ធ្វើការផងដែរខាង វីដេអូ សម្តែង និងសម្លេង។ អត្តសញ្ញាណរបស់សិល្បករូបនេះដែលជាជនជាតិដើម អូស្ត្រាលីនៃជាតិសាសន៍ប៊ីដចារ៉ាគឺជាលក្ខណៈស្នូលចំពោះស្នាដៃរបស់គាត់ដែលរុករកភាពស្មុគស្មាញនៃប្រវត្តិសាស្ត្រនិងភាពអត្តនោម័តក្រោយសម័យអាណានិគម ដែលមានលក្ខណៈភាគច្រើនបែបល្ខោន។ ថមសុនគឺជាជនជាតិដើមអូស្ត្រាលីទីមួយដែលត្រូវបានទទួលឱ្យចូលសិក្សានៅក្នុងសាកលវិទ្យាល័យអុកស្វត ដែលនៅទីនោះគាត់កំពុងព្យាយាមសិក្សាថ្នាក់បណ្ឌិត( ផ្នែកវិចិត្រសិល្បៈ )។ នៅក្នុងឆ្នាំ២០១២ ថមសុនបានធ្វើការពិព័រណ៍ យើងកប់ខ្លួនឯង ដោយព្រមពេលជាមួយគ្នានៅទីក្រុងអុកស្វត និងទីក្រុងមែលប៊ន អូស្ត្រាលី។ សេរីរូបភាពទាំងនេះ ត្រូវបានយកគំនិតតាមដោយ និងនៅក្នុងសំវាទជាមួយ សមុច្ច័យរបស់សារមន្ទីរអង់គ្លេសនូវរូបភាពនៃជនជាតិដើមអូស្ត្រាលីក្នុងសម័យអាណានិគម។ ដូចគ្នានឹងបណ្តាសិល្បករដែលជាជនជាតិដើមអូស្ត្រាលីជាច្រើនផ្សេងទៀតដែរវិធីធ្វើរបស់ថមសុនចោទសួរជាលក្ខណៈរិះគន់ចំពោះកំណត់ត្រាប្រវត្តិសាស្ត្រនៃអតីតអំណាចអាណានិគម។

សម្រាប់វត្ថុសិល្បៈថ្មីៗ ថមសុនផ្តល់នូវស្នាដៃសម្លេងមួយដែលចម្លងនូវរូបមន្តគណនារបស់ហ្វូងឃ្មុំ។ ស្នាដៃនេះ រួមមានពាក្យនិយាយរបស់សិល្បកររូបនេះជាភាសាប៊ីដចារ៉ាថា “muna” ( ឃ្មុំ ) និង “nguwal” ( ហ្វូងឃ្មុំ )។ ភាសាវិទូធ្វើការប៉ាន់ស្មានថា ពេលដែលជនជាតិអឺរ៉ុបបានមកដល់ប្រទេសអូស្ត្រាលីមានភាសាក្នុងស្រុកចំនួនជាង២៥០ភាសាត្រូវបាននិយាយ។ បច្ចុប្បន្ននេះ ភាសាទាំងនោះជាងពាក់កណ្តាលបានបាត់បង់ ដែលការបាត់បង់ភាសាជាច្រើនក្នុងចំណោមនោះគឺជាលទ្ធផលនៃគោលនយោបាយអាណានិគមដោយចេតនា ដែលជាញឹកញាប់ត្រូវបានយល់ថាជាទម្រង់មួយនៃអំពើប្រល័យពូជសាសន៍។

ឥឡូវនេះ សិល្បករ សកម្មជន និងអ្នកមានវិជ្ជាជ្រៅជ្រះដែលជាជនជាតិដើម កំពុងតវ៉ាយកភាសាជាច្រើនដែលត្រូវបានគិតថាកំពុងប្រឈមនឹងគ្រោះថ្នាក់និងបាត់បង់មកវិញ។ អ្នកជ្រុលនិយមត្រឹមត្រូវ គឺជាការប្រារព្ធសិល្បៈកវីនិពន្ធនៃភាសារបស់ថមសុន និងផ្តល់នូវឱកាសមួយសម្រាប់ការនឹកគិតបែបតាំងអារម្មណ៍។

# Christian Thompson

Although primarily known as a photographer, Christian Thompson also works in video, performance and sound. The artist's identity as an Indigenous Australian man of the Bidjara nation is central to his work, which explores the complexities of history and postcolonial subjectivity in an often theatrical manner. Thompson is the first Indigenous Australian to be admitted to the University of Oxford, where he is currently undertaking a Doctorate of Philosophy (Fine Art). In 2012 Thompson exhibited *We Bury Our Own* simultaneously at Oxford and in Melbourne, Australia; the series was inspired by and is in dialogue with a British museum's collection of colonial-era images of Indigenous Australians. Like many other Indigenous Australian artists, Thompson's practice critically interrogates the archives of the former colonial powers.

For ***new artefacts***, Thompson offers a sound piece that replicates the algorithms of a bee swarm. The work consists of the artist saying the words “muna” (bee) and “nguwal” (swarm of bees) in the Bidjara language. Linguists estimate that when Europeans arrived in Australia, over 250 Indigenous languages were spoken. Over half of them have now disappeared, many as a result of deliberate colonial policies that are often described as a form of genocide.

Indigenous artists, activists and scholars are now reclaiming many of the languages previously thought of as endangered and lost. *Decent Extremist* is a celebration of the lyricism of Thompson's language, and offers an opportunity for meditative contemplation.



គ្រីស្ទាន ថមសុន
អ្នកជ្រុលនិយមត្រឹមត្រូវ ២០១០
រូបភាពដែលមានប្រភពលើគេហទំព័រដោយគ្រីស្ទានថមសុន ជាមួយសេលីនវ៉ៅធ័រ
អនុញ្ញាតិឱ្យប្រើដោយសិល្បករ និងវិចិត្រសាល ហ្គាប្រ៊ីយែល ភីហ្ស៊ី មែលប៊ន អូស្ត្រាលី

Christian Thompson
*Decent Extremist*, 2010
Web sourced images by Christian Thompson with Celine Wouters
Courtesy of the artist and Gallery Gabrielle Pizzi, Melbourne, Australia

# ស-សបាសាក់ SA SA BASSAC

#18 Sothearos Boulevard, 2nd Floor
Phnom Penh, Kingdom of Cambodia
Open Thu-Fri 2pm-6pm, Sat-Sun 10am-6pm
and by appointment: +855 (0)17 774 864 | info@sasabassac.com
www.sasabassac.com

បកប្រែសៀវភៅបញ្ជីវត្ថុសិល្បៈដោយ លោក ស៊ុំ ស៊ីថែន

Catalogue translation by Mr Sum Sithen

*វត្ថុសិល្បៈថ្មីៗ*ត្រូវបានទ្រទ្រង់ដោយសប្បុរសដោយ:

***new artefacts*** is generously supported by:

Australian Embassy
Phnom Penh

INSTITUT FRANÇAIS
CAMBODGE

# កំណត់សម្គាល់ notes

# កំណត់សម្គាល់ notes

ស-សបាសាក់ SA SA BASSAC

Australian Embassy
Phnom Penh

INSTITUT FRANÇAIS
CAMBODGE